សម្រាប់កម្មករនិយោជិត និងនិយោជក

# ប្រាក់ឈ្នួលអាចទូទាត់តាមប្រព័ន្ធឌីជីថល!







ក្នុងច្បាប់ស្តីពីស្តង់ដារការងារ ប្រាក់ឈ្នួលជាគោលត្រូវទូទាត់ដោយសាច់ប្រាក់ ប៉ុន្តែប្រាក់ឈ្នួលក៏អាចត្រូវបានផ្ញើទៅគណនីធនាគារដែរ ក្នុងករណីមានការយល់ព្រមពីកម្មករនិយោជិត។ ដើម្បីបំពេញតាមតម្រូវការនៃការកើនឡើងការទូទាត់ដោយគ្មានសាច់ប្រាក់ និងការផ្តល់ជម្រើសច្រើននូវវិធីផ្ញើប្រាក់, ការទូទាត់ប្រាក់ឈ្នួលទៅគណនីរបស់ភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់*មួយចំនួនក៏នឹងត្រូវបានអនុញ្ញាតផងដែរ ក្នុងករណីមានការយល់ព្រមពីកម្មករនិយោជិត។

*មានតែភ្នាក់ងារផ្ទេរប្រាក់(ដូចជា ●●Pay) ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពប៉ុណ្ណោះ។
បញ្ជីនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ នឹងត្រូវបានដាក់លើគេហទំព័ររបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពក្រោយការសម្រេចរួច។

គេហទំព័ររបស់ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព

## លំដាប់លំដោយនាពេលខាងមុខ

| | |
|---|---|
| ខែមេសាឆ្នាំ2023 | ភ្នាក់ងារផ្ទេរប្រាក់ដាក់ពាក្យស្នើសុំទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព ហើយក្រសួងសុខាភិបាល ការងារ និងសុខុមាលភាពធ្វើការពិនិត្យ(អាចចំណាយពេលបីបួនខែ) |
| ▼ ក្រោយរដ្ឋមន្ត្រីសម្រេច | ចុះកិច្ចព្រមព្រៀងប្រើប្រាស់ពលកម្មតាមក្រុមហ៊ុននីមួយៗ |
| ▼ ក្រោយចុះកិច្ចព្រមព្រៀងប្រើប្រាស់ពលកម្ម | ពន្យល់កម្មករនិយោជិតម្នាក់ៗ និងចាប់ផ្តើមការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល ក្នុងករណីមានការយល់ព្រមពីកម្មករនិយោជិត |

## ▶ ប្រការប្រុងប្រយ័ត្ន

- ការទូទាត់ប្រាក់ឈ្នួលដោយពិន្ទុ ឬដោយរូបិយប័ណ្ណនិម្មិតដែលមិនអាចប្តូរទៅជាសាច់ប្រាក់ មិនត្រូវបានអនុញ្ញាតទេ។
- ការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល គឺជាជម្រើសមួយក្នុងចំណោមជម្រើសសម្រាប់វិធីទូទាត់និងទទួលប្រាក់ឈ្នួល។ សូម្បីតែនៅក្រុមហ៊ុនដែលបានប្រើប្រាស់ការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលក៏ដោយ ក៏មិនចាំបាច់ផ្លាស់ប្តូរវិធីទូទាត់និងទទួលប្រាក់ឈ្នួល បច្ចុប្បន្ននៃកម្មករនិយោជិតគ្រប់គ្នាទេ។
- ប្រសិនបើគ្មានបំណងទេ កម្មករនិយោជិតអាចបន្តទទួលប្រាក់ឈ្នួលតាមគណនីធនាគារដូចមកដល់បច្ចុប្បន្ន។ល។ ម្យ៉ាងទៀត និយោជកមិនត្រូវបង្ខំកម្មករនិយោជិតដែលគ្មានបំណង ឱ្យបើកប្រាក់ឈ្នួលរបស់ពួកគេតាមប្រព័ន្ធឌីជីថលនោះទេ។ (និយោជកអាចបំពានច្បាប់ស្តង់ដារការងារ និងត្រូវទទួលការពិន័យ ប្រសិនបើសាមីខ្លួនកម្មករនិយោជិតមិនយល់ព្រម ឬបានបង្ខំទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល។)
- កម្មករនិយោជិតក៏អាចទទួលបានប្រាក់ឈ្នួលមួយផ្នែកតាមគណនីនៃភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់ដែលបានកំណត់ ហើយផ្នែកនៅសល់ អាចទទួលតាមគណនីធនាគារជាដើមក៏បាន។

### កម្មករនិយោជិតមានបំណង

ប្រាក់ឈ្នួលមួយផ្នែក
គណនីនៃភ្នាក់ងារផ្ទេរប្រាក់ (ឧទាហរណ៍: 5ម៉ឺនយេន)

ប្រាក់ឈ្នួលនៅសល់
គណនីធនាគារជាដើម




### កម្មករនិយោជិតគ្មានបំណង

ប្រាក់ឈ្នួលទាំងអស់
គណនីធនាគារជាដើម



## អ្វីដែលយើងចង់ឱ្យអ្នកទាំងអស់គ្នាដឹងជាមុន ពេលមានបំណងទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថល

- **ចាំបាច់ចុះកិច្ចព្រមព្រៀងជាមុន**
  ក្នុងករណីបញ្ចូលការទូទាត់ប្រាក់ឈ្នួលតាមប្រព័ន្ធឌីជីថលក្នុងក្រុមហ៊ុនដំបូងឡើយ ចាំបាច់ត្រូវចុះកិច្ចព្រមព្រៀងប្រើប្រាស់ពលកម្មរវាងនិយោជកនិងកម្មករនិយោជិត។ ក្រោយមកនិយោជកត្រូវពន្យល់អំពីប្រការខាងក្រោមដល់កម្មករនិយោជិតនិងទទួលបានការយល់ព្រមពីកម្មករនិយោជិតម្នាក់ៗ។

- **កំណត់ដោយសមស្របនូវទឹកប្រាក់ទទួលបាន**
  សូមយល់ថាគណនីនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ គឺមិនមែនសម្រាប់"ដាក់ប្រាក់"នោះទេ ប៉ុន្តែសម្រាប់ការទូទាត់ និងការផ្ញើប្រាក់ ហើយសូមទទួលចំនួនទឹកប្រាក់ដែលអ្នករំពឹងថានឹងប្រើសម្រាប់ការទូទាត់ជាដើម។ លើសពីនេះ ចំនួនទឹកប្រាក់ដែលទទួលបាន ត្រូវតែក្រោមចំនួនដកអតិបរមាក្នុងមួយថ្ងៃ។

- **ទឹកប្រាក់អតិបរមានៃគណនីគឺ1លានយេនឬតិចជាងនេះ**
  ទឹកប្រាក់អតិបរមានៃគណនី ត្រូវបានកំណត់ត្រឹម1លានយេនចុះ។ ប្រសិនបើលើសចំនួនអតិបរិមា វានឹងដកប្រាក់ដោយស្វ័យប្រវត្តិទៅគណនីធនាគារដែលកំណត់ដោយកម្មករនិយោជិតជាមុន។ ក្នុងករណីនេះ ថ្លៃសេវាអាចជាបន្ទុករបស់កម្មករនិយោជិត ដូចនេះសូមបញ្ជាក់ជាមួយភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។

- **ក៏អាចដកសាច់ប្រាក់ពីសមតុល្យគណនីដែរ(មិនគិតថ្លៃសេវាដកប្រាក់ពីគណនី 1លើកក្នុងមួយខែ)**
  អ្នកក៏អាចដកសាច់ប្រាក់(ដកប្រាក់) ពីសមតុល្យគណនី ដោយដកប្រាក់នៅម៉ាស៊ីនATMគណនីធនាគារជាដើម។ កម្មករនិយោជិតអាចដកប្រាក់យ៉ាងហោចណាស់1លើកក្នុងមួយខែពីគណនីនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ ដោយឥតគិតថ្លៃសេវាឡើយ។ វិធីសាស្ត្រដកប្រាក់ និងថ្លៃសេវាប្រែប្រួលទៅតាមភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់។

- **រយៈពេលទូទាត់សងនូវសមតុល្យគណនី មានយ៉ាងហោចណាស់10ឆ្នាំ**
  តាមការស្នើសុំ,សមតុល្យគណនីអាចត្រូវបានទូទាត់សងវិញក្នុងរយៈពេលយ៉ាងហោចណាស់10ឆ្នាំ គិតចាប់ពីថ្ងៃដាក់ប្រាក់/ដកប្រាក់ចុងក្រោយ។

### ▶ ក្នុងករណីណាមួយ

- **ក្នុងករណីមានប្រតិបត្តិការក្លែងបន្លំ(ការដកប្រាក់ដោយមិនដឹង។ល។)**
  ក្នុងករណីមានការដកប្រាក់ដោយក្លែងបន្លំពីគណនីនៃភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ដោយសារការលួចគណនី។ល។ ទឹកប្រាក់ខាតបង់ទាំងស្រុងនឹងត្រូវបានផ្តល់សំណងប្រសិនបើម្ចាស់គណនីមិនមានកំហុស ប៉ុន្តែវាអាស្រ័យលើករណីបុគ្គលដោយឡែកសម្រាប់ការធានាប្រសិនបើកម្មករនិយោជិតដែលមានកំហុស។ វាមានរយៈពេលជូនដំណឹងយ៉ាងហោចណាស់30ថ្ងៃឡើង គិតចាប់ពីថ្ងៃខាតបង់។ ក្នុងករណីមានប្រតិបត្តិការក្លែងបន្លំ សូមទាក់ទងមកភ្នាក់ងារផ្ទេរប្រាក់ដែលបានកំណត់ភ្លាម។

- **ក្នុងករណីភ្នាក់ងារក្ស័យធន**
  ក្នុងករណីភ្នាក់ងារផ្តល់សេវាផ្ទេរប្រាក់ដែលបានកំណត់បានក្ស័យធន ស្ថាប័នធានានឹងធ្វើការទូទាត់។



ដើម្បីការរស់នៅនិងអនាគតនៃមនុស្ស
ក្រសួងសុខាភិបាល ការងារ
និងសុខុមាលភាព